# សារាចរ

## ស្តីពី

## សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
លេខៈ ០៤ សរច ៨៤

ភ្នំពេញ, ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ១៩៨៤

# សារាចរ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជំរាបមក**

សមមិត្តប្រធានតុលាការប្រជាជនខេត្ត ក្រុង

សមមិត្តរដ្ឋអាជ្ញាអមតុលាការប្រជាជនខេត្ត ក្រុង

**កម្មវត្ថុ** ៈ សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី

ក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅនេះ អយ្យការ និងតុលាការប្រជាជនខេត្ត ក្រុង បានដំណើរការ និងបានអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ ។ ក្នុងវិស័យព្រហ្មទណ្ឌ ការចោទប្រកាន់ និងការបើកសវនាការជំនុំជំរះ បាននាំមកនូវឥទ្ធិពលយ៉ាងល្អប្រពៃ ក្នុងការរួមចំណែកការពារ និងកសាងមាតុភូមិ ជាពិសេសក្នុងការការពារសន្តិសុខសង្គម របៀបរៀបរយសាធារណៈ ការពារទ្រព្យសម្បត្តិរដ្ឋ ការពារអាយុជីវិត និងទ្រព្យសម្បត្តិស្របច្បាប់របស់ពលរដ្ឋ ។

ក្នុងវិស័យរដ្ឋប្បវេណី អាពាហ៍ពិពាហ៍ និងគ្រួសារ តុលាការប្រជាជនខេត្ត ក្រុងក៏បានដំណើរការផ្សះផ្សារគូភាគីឱ្យជានានឹងគ្នាឡើងវិញ បានជាច្រើនរឿង សំដៅធ្វើឱ្យប្រជាជនមានសាមគ្គីភាពឯកភាពគ្នារួមកំលាំងគ្នាជំរុញការបង្កបង្កើនផល និងថែរក្សាស្ថេរភាពនៃការរស់នៅរបស់ខ្លួន ។

ប៉ុន្តែទន្ទឹមនឹងលទ្ធផលដ៏ប្រពៃដែលអយ្យការ និងតុលាការប្រជាជនខេត្ត ក្រុង ដណ្តើមបាននោះ ក្រសួងយុត្តិធម៌ក៏បានមើលឃើញការលំបាក និងភពស្មុគ្រស្មាញមួយចំនួន ក្នុងការងាររបស់តុលាការប្រជាជន ផ្នែករដ្ឋប្បវេណីដែរ ។ តុលាការប្រជាជនផ្នែករដ្ឋប្បវេណី ពុំទាន់បានបើសវនាការជំនុំជំរះរឿងរដ្ឋប្បវេណី រឿងអាពាហ៍ពិពាហ៍ និងគ្រួសារឡើយ ធ្វើឱ្យរឿងប្រភេទនេះដែលផ្សះផ្សាពុំបានសំរេចនោះ នៅសល់កាន់តែច្រើនឡើងៗ ។ បាតុភាពនេះបើមាន

តទៅទៀតជាហេតុមួយនាំឱ្យប្រជាជន ថ្នាំងថ្នាក់ចិត្ត និងអស់ជំនឿលើតុលាការប្រជាជន ក្នុងដំណោះស្រាយរឿងទំនាស់របស់គេ ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងយុត្តិធម៌សំរេចចេញសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី ដែលមានដូចខាងក្រោមនេះ :

## I ~ អំពីការផ្សះផ្សា :

ក្រោយពីបានទទួលបណ្តឹងពីសាម៉ីជនដោយផ្ទាល់ ឬពីអង្គការយុត្តិធម៌មូលដ្ឋាន ឬអង្គការណាមួយ ប្រធានតុលាការត្រូវចាត់ឱ្យចុះបណ្តឹងនោះ ក្នុងសៀវភៅទទួលបណ្តឹង ។ ប្រធានតុលាការត្រូវពិនិត្យមើល ថាតើរឿងដែលប្តឹងនោះស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនដែរឬទេ?

ប្រសិនបើរឿងនោះមានលក្ខណៈជារឿងរដ្ឋបាល ត្រូវផ្ទេររឿងនោះទៅឱ្យអង្គការរដ្ឋបាល ដែលមានសមត្ថកិច្ចដើម្បីដោះស្រាយ ។

ប្រសិនបើរឿងនោះ មានលក្ខណៈជារឿងព្រហ្មទណ្ឌ ត្រូវផ្ទេររឿងនោះទៅឱ្យអយ្យការ ដើម្បីដោះស្រាយ ។

ប្រសិនបើបណ្តឹងនោះ មានលក្ខណៈជារឿងរដ្ឋប្បវេណី ឬ អាពាហ៍ពិពាហ៍ និងគ្រួសារ ប្រធានតុលាការត្រូវចាត់អោយចៅក្រមម្នាក់ ទទួលបន្ទុកពិនិត្យសំណុំរឿង ដើម្បីធ្វើការផ្សះផ្សាជាបន្ទាន់ ។ ភារកិច្ចផ្សះផ្សានេះប្រធានតុលាការត្រូវធ្វើដោយខ្លួនឯង កាលបើពិនិត្យឃើញថាជាការចាំបាច់ ។

នៅថ្ងៃកំណត់ធ្វើការផ្សះផ្សា ប្រសិនបើភាគីម្ខាងមិនបានទទួលលិខិតអញ្ជើញនោះគឺត្រូវអញ្ជើញភាគីទាំងអស់ឱ្យចូលមកសាជាថ្មីម្តងទៀត នៅថ្ងៃណាមួយផ្សេងទៀត ។

ប្រសិនបើដើមចោទ បានទទួលិខិតអញ្ជើញហើយ ហើយមិនបានចូលមកដោយគ្មានមូលហេតុចំនួន ២ លើកនោះ ត្រូវចាត់ទុកថាភាគីនេះបោះបង់បណ្តឹងរបស់ខ្លួន ។ ក្នុងករណីនេះចៅក្រម ត្រូវធ្វើដីកាចំណាយរឿងចេញពីបញ្ជី ។

នៅថ្ងៃកំណត់ធ្វើការផ្សះផ្សាបើភាគីទាំងអស់បានចូលមក ចៅក្រម ត្រូវណែនាំសំរុះសំរួលយ៉ាងណាឱ្យគូភាគីបានជានឹងគ្នាវិញ ដោយវិចារណញ្ញាណ ។ ណែនាំអោយគូភាគីមើលឃើញនូវផលវិបាកទាំងឡាយ ដែលកើតចេញមកពីការទាស់ទែងគ្នា ការបាក់បែកសាមគ្គី និងការខាតពេលវេលា និងផលប្រយោជន៏ក្នុងការបន្តរឿងក្តីវែងអន្លាយតទៅទៀត ។

ចៅក្រម មិនត្រូវធ្វើការគៀបសង្កត់ គំរាមកំហែង ឬបង្ខិតបង្ខំអោយភាគីណាមួយសំរេចចិត្តយ៉ាងនេះ ឬយ៉ាងនោះឡើយ ។ ក្នុងការផ្សះផ្សា ដាច់ខាតត្រូវអោយស្របច្បាប់ផងដែរ ។ ការផ្សះផ្សាមិនស្របច្បាប់ ត្រូវ

ហាមឃាត់ ឧទាហរណ៍អ្នកលេងបៀរឈ្នះ ប្តឹងឱ្យអ្នកលេងចាញ់សងប្រាក់មកអោយខ្លួន ឬការប្តឹងលែងលះគ្នា ប្តីសុំអោយប្រពន្ធប្រគល់កូននៅបៅដោះ មកឱ្យខ្លួនចិញ្ចឹម ។ ករណីទាំងនោះតុលាការ មិនត្រូវដោះស្រាយទេ ។

ជាពិសេស ក្នុងដំណាក់ការផ្សះផ្សា ចៅក្រមមិនត្រូវពិនិត្យដល់អង្គសេចក្តីនៃរឿងទេ បានន័យថាមិនត្រូវពិនិត្យរកហេតុផល រកភស្តុតាង ថាភាគីនេះត្រូវឈ្នះ ភាគីនោះត្រូវចាញ់ឡើយ ។

ក្នុងការផ្សះផ្សា ទោះជាបានសំរេចក្តី មិនបានសំរេចក្តី ត្រូវតែធ្វើកំណត់ហេតុចុះទាំងស្រុងក្នុងសៀវភៅកំណត់មួយពិសេស សំរាប់ការផ្សះផ្សា ។

បើគូភាគីយល់ព្រមជានឹងគ្នាវិញ នោះកំណត់ហេតុ ត្រូវបញ្ជាក់អោយបានត្រឹមត្រូវនូវកិច្ចសន្យា (      ) ដែលគូភាគីទទួលយល់ព្រម ពីព្រោះកិច្ចសន្យានេះចងភ្ជាប់គូភាគីកុំឱ្យប្រកែកកែប្រែបាន ។ ចៅក្រម ត្រូវចេញដីកាសំរេចលាតត្រដាងឡើងវិញនូវកិច្ចសន្យានោះ ។ ដីការនោះមានតម្លៃស្មើនឹងសាលក្រមស្ថាពរដែរ ។

បើគូក្តីមិនព្រមជានឹងគ្នា ឬ បើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ហើយមិនបានចូលខ្លួនមកដោយគ្មានមូលហេតុ ចំនួនពីរលើ នោះចៅក្រមត្រូវចាត់ឱ្យធ្វើកំណត់ហេតុអំពីករណីនេះ ដាក់ចូលក្នុងសំណុំរឿង ហើយត្រូវចាត់វិធានការធ្វើការអង្កេតស៊ើបសួរ គឺត្រូវចាត់ចែងរៀបចំសំណុំរឿងឱ្យបានសព្វគ្រប់មុននឹងដាក់រឿងនោះទៅជំនុំជំរះ ។

ចំពោះរឿងលែងលះគ្នា ការផ្សះផ្សា ត្រូវធ្វើនីតិវិធី ដែលមានចែងក្នុងច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ នៅពេលដែលច្បាប់នេះចូលជាធរមាន ។

នៅពេលសវនាការ មុនពេលជំនុំជំរះដល់អង្គសេចក្តីនៃរឿងតុលាការអាចធ្វើការផ្សះផ្សាម្តងទៀតបាន ។

ក្នុងរឿងខ្លះដែលមានភាគីតែម្ខាង គឺមានតែដើមបណ្តឹង ដូចជាបណ្តឹងសុំកែប្រែ ឬសុំចុះកំណើត សុំកែប្រែ ឬសុំចុះមរណភាព ប្តឹងសុំសាលក្រមប្រកាសបាត់ខ្លួននៃសហព័ទ្ធជាដើម តុលាការមិនបាច់ធ្វើការផ្សះផ្សាទេ តុលាការត្រូវចេញសាលក្រមសំរេចតែម្តង ។

ត្រូវកត់សំគាល់ថា មុននឹងធ្វើការអង្កេតស៊ើបសួ ត្រូវបង្គាប់អោយដើមចោទបង់ប្រាក់ក្រឡាក្រម ដែលនឹងកំណត់ក្នុងច្បាប់ ។

## II ~ អំពីការអង្កេតស៊ើបសួរ

បើការផ្សះផ្សារពុំអាចប្រព្រឹត្តទៅបាន ឬបានប្រព្រឹត្តទៅ តែពុំបានលទ្ធផល ចៅក្រមត្រូវធ្វើការអង្កេតស៊ើបសួរ និងពិនិត្យឱ្យបានល្អិតល្អន់ អំពីខ្លឹមសារនៃរឿង និងនីតិវិធីចាំបាច់ក្នុងការដោះស្រាយ ។ ការអង្កេតស៊ើបសួរ ក្នុងនីតិវិធីរដ្ឋប្បវេណី មានលក្ខណៈខុសប្លែកពីការអង្កេតស៊ើបសួរ ក្នុងនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងរឿងព្រហ្មទណ្ឌ គឺស្ថាប័នសន្តិសុខ នគរបាលអយ្យការ ជាអង្គការទទួលបន្ទុកធ្វើការអង្កេតស៊ើបសួរ ។

រីឯក្នុងរឿងរដ្ឋប្បវេណី ចៅក្រមជាអ្នកទទួលបន្ទុកធ្វើការអង្កេតស៊ើបសួរស្រាវជ្រាវរកគ្រប់ភស្តុតាង និងមូលដ្ឋានច្បាប់ ដើម្បីរៀបចំសំណុំរឿងនោះទៅជំនុំជំរះ ។ បញ្ហានេះអាចនាំឱ្យមានបាតុភាពមួយខាងសតិអារម្មណ៍កើតឡើង គឺចៅក្រមច្រើនមើលស្រាលក្នុងការពិនិត្យឡើងវិញនូវនីតិវិធី និងខ្លឹមសារនៃរឿង ដោយទុកចិត្តថាក្នុងពេលផ្សះផ្សា ខ្លួនបានពិនិត្យគ្រប់ជ្រុងជ្រោយហើយ ។ ដើម្បីចៀសវាងនូវបាតុភាពនេះ ចៅក្រម ត្រូវយកចិត្តទុកដាក់លើបញ្ហាដូចខាងក្រោមនេះ :

១- ចៅក្រម ត្រូវមើលអំពីទំនាក់ទំនងគតិយុត្តិ រវាងដើមចោទ និងចុងចម្លើយ ដូចជាក្នុងរឿងអាពាហ៍ពិពាហ៍ ត្រូវកំណត់អោយច្បាស់ អំពីចំណងទាក់ទងបុរស និង ស្ត្រី ដែលប្តឹងសុំថាសមគួរសង្វាសគ្នា ថាតើបុរសនិង នារីនោះមានចំណងអាពាហ៍ពិពាហ៍ឬទេ? និងអំពីចំណងទាក់ទង រវាងឪពុក ឬ ម្តាយ ជាមួយនឹងកូន ។ ទន្ទឹមនឹងនោះក៏ត្រូវកំណត់ឱ្យច្បាស់ អំពីទំនាក់ទំនងក្នុងវិស័យទ្រព្យសម្បត្តិថែមទៀត ។

ការកំណត់ទំនាក់ទំនងគតិយុត្តិក្នុងរឿងរដ្ឋប្បវេណី មានសារៈសំខាន់ ក្នុងពេលអង្កេតស្រាវជ្រាវ ធ្វើសំណុំរឿងឱ្យគ្រប់ជ្រុងជ្រោយ ក៏ដូចជាក្នុងពេលជំនុំជំរះ ពីព្រោះដោយផ្អែកលើកត្តានេះហើយ ដែលចៅក្រម ឬតុលាការអាចប្រមូលរកភស្តុតាងជាមូលដ្ឋានបាន ដើម្បីដោះស្រាយរឿងនោះឱ្យបានត្រឹមត្រូវ ។

២-ក្រោយពីបានកំណត់ទំនាក់ទំនងគតិយុត្តិហើយ ចៅក្រម ត្រូវចាត់ឱ្យលេខាធិការក្រឡាបញ្ជីកោះអញ្ជើញភាគី និងសាក្សីទាំងឡាយ មកបង្ហាញខ្លួន ហើយសួរយកចម្លើយពីជនទាំងនោះ ។ ទន្ទឹមនឹងនេះ ក៏ត្រូវជូនដំណឹងដល់មេធាវីរបស់គូភាគីផងដែរ អំពីវិធានការស៊ើបសួរ ហើយមេធាវីនោះមានសិទ្ធិ ចូលរួមក្នុងការអង្កេតស៊ើបសួរគ្រប់ពេលវេលា និងមានសិទ្ធិប្តឹងជំនួសកូនក្តីខ្លួនបាន បើកូនក្តីបានប្រគល់សិទ្ធិនេះឱ្យខ្លួន ។ មេធាវី អាចជូនសេចក្តីសន្និដ្ឋាន និងសារណាទាំងឡាយ ចាប់តាំងពីពេលដែលគូក្តីបានពឹងខ្លួន រហូតដល់ពេលបញ្ចប់ការសួរដេញដោលមុនពេលចេញសាលក្រម ។

តាំងពីពេលដាក់ពាក្យបណ្តឹងរហូតដល់ពេលសួរដេញដោល ដើមបណ្តឹងមានសិទ្ធិបន្ថែម ឬ បន្ថយពាក្យបណ្តឹងរបស់ខ្លួន ។ រីឯចុងចម្លើយក៏មានសិទ្ធិដាក់ពាក្យប្តឹងតបវិញដែរ ប៉ុន្តែបណ្តឹងតបនេះ ត្រូវមានទំនាក់ទំនងគ្នានឹងបណ្តឹងដើមមានមូលហេតុក្នុងបណ្តឹងដើម ឬ ជាមធ្យោបាយការពារទល់នឹងបណ្តឹងដើម ។

ក្នុងការធ្វើកំណត់ហេតុផ្សះផ្សាក៏ដូចជាការស្រង់ចម្លើយរបស់ភាគី ឬសាក្សីនៅពេលអង្កេតស៊ើបសួរ ត្រូវសរសេរឱ្យច្បាស់ គ្មានការឆូតលុប ហើយជួសបន្ថែមពាក្យឡើយ ។

បើលុប ឬបន្ថែមពាក្យ ត្រូវដាក់និទ្ទេស "យល់ព្រមលុប" ឬ "យល់ព្រមបន្ថែម" រួចចៅក្រមលេខាធិការក្រឡាបញ្ជី និងជនដែលបានឆ្លើយ ត្រូវចុះហត្ថលេខានៅក្រោមនិទ្ទេសនេះ ។

ការអង្កេតស៊ើបសួរ ត្រូវធ្វើចំពោះមុខគូភាគី និងចំពោះមុខអ្នកការពាររបស់គូភាគីប្រសិនបើមាន ។ ត្រូវសួរសាក្សីម្នាក់ម្តង ទោះចំពោះមុខគូភាគីក្តី កំបាំងមុខក្តី ។

ក្នុងការចាំបាច់ ដើម្បីរកការពិត ចៅក្រម អាចសួរចម្លើយតទល់រវាងសាក្សី ឬរវាងភាគី និងសាក្សីបាន ។

៣-ចៅក្រម ត្រូវបង្គាប់ឱ្យដាក់ចូលក្នុងសំណុំរឿង នូវលិខិតទាំងឡាយដែលមានប្រយោជន៍ ដើម្បីបំភ្លឺតុលាការ ។ ចៅក្រម ត្រូវពិនិត្យមើលតែភស្តុតាងទាំងឡាយ ដែលគូក្តីជូនមកអាងនោះ គ្រប់គ្រាន់ហើយឬនៅ? ។ បើពិនិត្យឃើញថាភស្តុតាងនោះនៅមានខ្វះចន្លោះត្រង់ចំណុចណាមួយ នោះចៅក្រមគប្បីចាត់ការអង្កេតស្រាវជ្រាវថែមទៀត ឬក៏ចាត់ឱ្យភាគីដែលលើកបញ្ហាណាមួយមកអាងនោះ យកភស្តុតាងមកដាក់ក្នុងសំណុំរឿងក៏បាន ។

បើក្នុងសំណុំរឿងមានកើតបញ្ហាដែលជាចាំបាច់ត្រូវមានអ្នកជំនាញជួយពិនិត្យវិភាគ និងកំណត់នោះចៅក្រមគប្បីចាត់តាំងអោយមានអ្នកជំនាញ ធ្វើកោសល្យវិច័យបញ្ជាក់ជាលាយល័ក្ខអក្សរ និងចុះហត្ថលេខាត្រឹមត្រូវ ។ លទ្ធផលនៃការសន្និដ្ឋានរបស់អ្នកជំនាញក្នុងលិខិតកោសល្យវិច័យ ពុំមែនជាកត្តាកំណត់ ដែលចៅក្រម ឬតុលាការប្រជាជន ត្រូវតែសំរេចតាមនោះទេ ។ ចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ អាចចាត់តាំងឱ្យមានអ្នកជំនាញផ្សេងទៀតធ្វើកោសល្យវច័យថែម កាលបើចៅក្រមយល់ឃើញថា ការសន្និដ្ឋានក្នុងលិខិតកោសល្យវិច័យមុន នៅមានភាពពុំទាន់ច្បាស់លាស់ ។

ក្នុងរយៈពេលស៊ើបអង្កេតស្រាវជ្រាវភស្តុតាង ចៅក្រមចាំបាច់ត្រូវពិនិត្យយ៉ាងល្អិតល្អន់លើវត្ថុតាង (ឯកសារសំបុត្រ ឬវត្ថុផ្សេងៗ) ចំលើយរបស់ភាគីចម្លើយរបស់សាក្សី លិខិតកោសល្យវិច័យ និងឯកសារដទៃទៀត ដែលអង្គការរដ្ឋ ឬអង្គការមហាជនធ្វើ និងប្រគល់អោយ ។

ភស្តុតាងនីមួយៗ ត្រូវយកមកព្រៀបធៀបនឹងផស្តុតាងឯទៀត ដើម្បីវាយតម្លៃសរុបអោយឃើញថាភស្តុតាងទាំងនោះ បានស្របនឹងគ្នាហើយ ហើយបញ្ជាក់អោយឃើញរការពិតគ្រប់ជ្រុងជ្រោយប្រាកដមែន ។ ប្រសិនបើភស្តុតាងទាំងអស់ដែលប្រមូលបានក្នុងសំណុំរឿងនៅមិនទាន់ច្បាស់ត្រង់ចំណុចណាមួយនោះ ចៅក្រមអាចធ្វើការអង្កេតបន្ថែម ដោយចុះទៅដល់ទីកន្លែងកើតហេតុ ដើម្បីរកអោយឃើញភាពជាក់ស្តែងថែមទៀត ។

៤-ក្រោយពិនិត្យលើភស្តុតាងសព្វគ្រប់ហើយ ចៅក្រម ត្រូវយកភស្តុតាងទាំងនោះ និងសំណូមពររបស់គូភាគីធ្វើជាមូលដ្ឋាន ហើយស្រាវជ្រាវរកមើលតើមូលដ្ឋាននោះសមស្របតាមច្បាប់កំណត់ តាមគោលនយោបាយរបស់បក្សដែរឬទេ? ។ ក្នុងករណីនេះ ចៅក្រមត្រូវយកអត្ថបទដែលមានចែង អំពីបញ្ហានៃរឿងនោះ មកពិនិត្យយ៉ាងល្អិតល្អន់ គឺត្រូវជៀសវាងកុំអាងទៅលើការចាំរបស់ខ្លួន ឬទំលាប់របស់ខ្លួន ដែលបានធ្វើពីមុនមក ។

៥-ក្រោយពីអង្កេតស៊ើបសួរចប់សព្វគ្រប់ហើយ ចៅក្រមត្រូវធ្វើរបាយការណ៍ភ្ជាប់ជាមួយសំណុំរឿង បញ្ជូនទៅតុលាការជំនុំជំរះ ។

ប្រធានតុលាការ ត្រូវចេញដីការ ចាត់តាំងចៅក្រមម្នាក់ ឬ ចាត់តាំងខ្លួនឯងធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជំរះ ។

## III ~ អំពីការត្រៀមបំរុង មុននឹងដាក់សំណុំរឿងជំនុំជំរះ

ចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ មានភារកិច្ចដូចតទៅ:

### ១-ការសុំយោបល់ពីតំណាងអយ្យការ

ចៅក្រម ត្រូវដាក់ជូនរដ្ឋអាជ្ញា ពិនិត្យ និង ផ្តល់យោបល់ជាលាយលក្ខអក្សរនូវសំណុំរឿងទាំងឡាយ ដែលទាក់ទងដល់របៀបរៀបរយសាធារណៈ ឬទ្រព្យសម្បត្តិរដ្ឋ ជាប់ជំពាក់ដល់ផលប្រយោជន៍អនីតិជន ឬអសមត្ថជន ។ ក្នុងករណីនេះ រដ្ឋអាជ្ញា ត្រូវធ្វើអន្តរាគមន៍ដោយតាំងខ្លួនជាគូក្តីដើម ហើយចាំបាច់ត្រូវចូលរួមក្នុងសវនាការ ។

ក្រៅពីសំណុំរឿងខាងលើនេះ ចៅក្រម ត្រូវដាក់ជូនរដ្ឋអាជ្ញាផងដែរ នូវសំណុំរឿងណាមួយ ដែលរដ្ឋអាជ្ញាសុំយកមកពិនិត្យ និងធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរលើរឿងនោះ ។

ចំពោះរឿងណាដែលចៅក្រម ឃើញថាមានលក្ខណៈជារឿងព្រហ្មទណ្ឌនោះចៅក្រម ត្រូវផ្ទេររឿងមកអោយអយ្យការ ដើម្បីធ្វើការចោទប្រកាន់ ។

ប៉ុន្តែបើតំណាងអយ្យការ ក្រោយពីបានពិនិត្យសំណុំរឿង ឃើញថារឿងនេះមានលក្ខណៈជារឿងរដ្ឋប្បវេណី ឬរឿងគ្រួសារទៅវិញ នោះអង្គការទាំងពីរត្រូវលើកមតិមិនឯកភាពគ្នានោះ ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសំរេច ។

### ២-ការសំរេចយករឿងដាក់ជំនុំជំរះ

ក- បន្ទាប់ពីបានបំពេញភារកិច្ចខាងលើសព្វគ្រប់ហើយ ចៅក្រម ត្រូវចេញដីកា សំរេចដាក់រឿងទៅជំនុំជំរះក្នុងដីកានោះ ត្រូវសរសេរឱ្យច្បាស់ :

- នាមត្រកូល អាយុ របររកស៊ី និងអាស័យដ្ឋាន របស់គូភាគី (ដើមចោទ និងចុងចម្លើយ) និងកម្មវត្ថុនៃរឿង ដូចជាការសុំដាច់សមគ្គសង្វាស ការសុំអោយចិញ្ចឹមអាហារកិច្ច ការសុំអោយសងប្រាក់តាមកិច្ចសន្យា ។ល។

- ឈ្មោះអ្នកការពារដើមចោទ ឬអ្នកការពារចុងចម្លើយ ប្រសិនបើមាន

- សំណូមពររបស់តុលាការប្រជាជន ដល់តំណាងសហគ្រាស ក្រុមសាម្គី ឬ តំណាងអង្គការមហាជន ចំពោះរឿងណាដែលតុលាការ ពិនិត្យឃើញថាចាំបាច់ ត្រូវតំណាងនៃអង្គការទាំងនោះ មកឆ្លើយបំភ្លឺតុលាការ ឬការពារផលប្រយោជន៍ របស់អង្គការទាំងនោះ ។

-ឈ្មោះអ្នកជំនាញ ដែលធ្វើកោសល្យវិច័យ ប្រសិនបើមាន ។

-ឈ្មោះអ្នកបកប្រែភាសា ប្រសិនបើមាន ។

-ពេលវេលា និងទីកន្លែងបើសវនាការ ។

-វត្ថុតាងដែលសាម៉ីជន ត្រូវនាំយកមកបង្ហាញតុលាការ នៅពេលសវនាការ ។

-គ្រប់ដីការសំរេចយករឿងដាក់ជំនំជំរះ ត្រូវចម្លងមួយសន្លឹកជូនតំណាងអយ្យការដើម្បីជ្រាប ។

ខ- លេខធិការ-ក្រឡាបញ្ជី ដោយអនុវត្តតាមដីកាខាងលើនេះ ត្រូវធ្វើលិខិតអញ្ជើញ-ជនដែលទាក់ទងក្នុងរឿង ឱ្យចូលរួមទាំងអស់ក្នុងសវនាការ ។ លេខាធិការក្រឡាបញ្ជី ជៀសវាងកុំអញ្ជើញតាមអត្តនោម័តរបស់ខ្លួន ហើយឈានដល់មានកង្វះ ដូចជាអញ្ជើញសាក្សីមិនគ្រប់ អញ្ជើញសាក្សីមិនចាំបាច់ ឬពុំបានប្រាប់សាម៉ីជនឱ្យយកវត្ថុតាងមកចំពោះមុខតុលាការ នៅពេលសវនាការ ។

គ- ក្នុងលិខិតអញ្ជើញ ត្រូវសរសេរឱ្យច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាម៉ីជន ហើយត្រូវធ្វើជាពីរច្បាប់ គឺមួយច្បាប់ប្រគល់អោយសាម៉ីជន មួយច្បាប់ទៀត អ្នកប្រគល់លិខិតអញ្ជើញ ត្រូវបង្វិលអោយតុលាការវិញដើម្បីដាក់ក្នុងសំណុំរឿង ។

លិខិតអញ្ជើញ ត្រូវចេញដោយគិតដល់ពេលវេលា ដែលសាម៉ីជនត្រូវទទួល ហើយអាចមកចូលរួមក្នុងសវនាការបាន ។

ឃ- យោងតាមករណីនីមួយៗ បុគ្គលិករបស់តុលាការ អាចប្រគល់លិខិតអញ្ជើអោយដល់សាម៉ីជន ឬប្រគល់ភារកិច្ចរបស់តុលាការ អាចប្រគល់លិខិតអញ្ជើញអោយដល់សាម៉ីជន ឬ ប្រគល់ភារកិច្ចនោះ អោយទៅសមាជិកយុត្តិធម៌ឃុំ ឬសង្កាត់ ។ ប្រសិនបើសាម៉ីជនជាកម្មាភិបាល បុគ្គលិក កម្មករ ក្នុងអង្គភាពណាមួយនោះលិខិតអញ្ជើញអាចផ្ញើទៅដល់សាម៉ីជនតាមរយៈប្រធានអង្គភាពនោះ ។

**៣-ការចាត់តាំងទីប្រឹក្សាប្រជាជន :**

ក្រោយពេលចេញដីកាសំរេច ដាក់រឿងទៅជំនុំជំរះចៅក្រមត្រូវចេញដីការចាត់តាំងទីប្រឹក្សាប្រជាជន ២ រូប ក្នុងចំណោមទីប្រឹក្សាដែលមានឈ្មោះក្នុងបញ្ជីរាយនាមទីប្រឹក្សាប្រជាជន ។ ទីប្រឹក្សាប្រជាជនទាំងពីររូបនេះត្រូវបានអញ្ជើញមកពិនិត្យសំណុំរឿងយ៉ាងតិចណាស់ ៣ ថ្ងៃ មុនថ្ងៃបើកសនាការ ដោយមិនគិតថ្ងៃឈប់សំរាកនិងថ្ងៃបុណ្យ ។

ចំពោះរឿងណាដែលមានលក្ខណៈស្មុគ្រស្មាញ ចៅក្រមត្រូវអធិប្បាយពន្យល់ទីប្រឹក្សាប្រជាជន អោយបានជ្រាបអំពីខ្លឹមសារនៃរឿង បញ្ញត្តិ និងគោលនយោបាយរបស់បក្ស ដើម្បីឱ្យទីប្រឹក្សាមានលទ្ធភាពរួមចំណែកក្នុងពេលជំនុំជំរះបានលទ្ធភាពល្អប្រសើរ ។

ចំណុចសំខាន់ ចៅក្រមត្រូវចេញណែនាំទីប្រឹក្សាអោយស្គាល់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដែលមានស្មើនឹងចៅក្រម សំដៅពង្រឹងសិទ្ធិធ្វើជាម្ចាស់របស់ប្រជាជន និងពង្រឹងនីត្យនុកូលភាពប្រជាធិបតេយ្យ ។

ជាពិសេសចៅក្រម និងទីប្រឹក្សាប្រជាជន មានកាតព្វកិច្ចរក្សាការសម្ងាត់របស់រដ្ឋ គឺមិនត្រូវឱ្យជនដទៃដឹងនូវរឿងដែលនឹងត្រូវជំនុំជំរះនោះទេ ។

ចៅក្រម ត្រូវព្រាងសំណួរ សំរាប់សួរបញ្ជាក់ដល់អ្នកចូលរួមក្នុងនីតិវិធីនៅពេលសវនាការខាងមុខ ។

## IV. អំពីការងារនៅពេលសវនាការ

ការបើកសវនាការ របស់តុលាការប្រជាជន មានគោលដៅជំនុំជំរះរឿងអោយបានល្អតល្អន់ និងត្រឹមត្រូវបំផុតតាមបញ្ញត្តិច្បាប់ និងតាមគោលនយោបាយរបស់បក្ស ។ ដូចនេះ នៅពេលសវនាការ តុលាការប្រជាជនត្រូវសួរចម្លើយ អ្នកចូលរួមក្នុងនីតិវិធីទាំងអស់សារឡើងវិញទាំងស្រុង ហើយបង្ហាញភស្តុតាងអោយបានសព្វគ្រប់ដើម្បីផ្អែកលើនោះតុលាការអាចនឹងចេញសេចក្តីប្រកាសសាលក្រមមួយ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ ។ ម្យ៉ាងវិញទៀតនៅពេលបើកសវនាការជំនុំជំរះ តុលាការ ត្រូវធ្វើយ៉ាងណាអោយការងារជំនុំជំរះ ក្លាយទៅជាការងារមួយអាប់រំដល់សាមីជនផង អប់រំដល់ប្រជាជនទូទៅផង អំពីសម្បជញ្ញៈ អំពីការអនុវត្តន៍ច្បាប់ និងគោលមាគ៌ារបស់បក្ស ។

តុលាការប្រជាជន គួរចៀសវាង និងកុំយល់ច្រឡំថា ខ្លួនបានធ្វើការផ្ទះផ្ទាជាច្រើនលើក ហើយការអង្កេតស៊ើបសួរក៏បានល្អតល្អន់ ហើយសំណុំរឿងរៀបចំក៏បានគ្រប់ជ្រុងជ្រោយហើយ ដូច្នេះការបើសវនាការ គ្រាន់តែជារូបភាពមួយថ្មីមួយកំណត់ការដោះស្រាយប៉ុណ្ណោះ ។ ទស្សនៈភាន់ច្រឡំនេះ អាចនាំដល់ការមើលស្រាលលើការសួរដេញដោលនៅពេលសវនាការ ការស្រាវជ្រាវពិនិត្យវត្ថុតាង និងមតិរបស់អ្នកចូលរួមក្នុងនីតិវិធីដូចជាមតិរបស់តំណាងអង្គការរដ្ឋ អង្គការសង្គម ឬរបស់អ្នកជំនាញ ។ នៅពេលសវនាការប្រធានក្រុមប្រឹក្សាជំនុំជំរះជាប្រធានសវនាការ ។ មានន័យថា ប្រធានក្រុមប្រឹក្សាជំនុំជំរះ មានអំណាចពេញសិទ្ធិក្នុងការដឹកនាំសវនាការ គឺធានាអោយបាននូវសណ្តាប់ធ្នាប់ក្នុងសវនាការ ។ បើមានជនណាម្នាក់ប្រព្រឹត្តខុសនឹងបទបញ្ជាផ្ទៃក្នុងនៃសវនាការ នោះប្រធានក្រុមប្រឹក្សាជំនុំជំរះ មានសិទ្ធិព្រមាន ឬបង្គាប់អោយអ្នករក្សាសណ្តាប់ធ្នាប់បង្ខំអោយជននោះ ចេញមួយរយៈ ឬ រហូតពីបន្ទប់ជំនុំជំរះជាបន្ទាន់ ។

ប្រសិនបើមានបទល្មើសព្រហ្មទណ្ឌណាមួយ កើតមានក្នុងបរិវេណនៃបន្ទប់ជំនុំជំរះ ហើយក្នុងអំឡុងពេលជំនុំជំរះ ប្រធានក្រុមប្រឹក្សាជំនុំជំរះ ត្រូវបញ្ជាឱ្យលេខាធិការ-ក្រឡាបញ្ជីធ្វើកំណត់ហេតុបញ្ជូនជនល្មើស និងវត្ថុតាងទៅអយ្យការ ដើម្បីចាត់វិធានការ ស៊ើបអង្កេត និងចោទប្រកាន់តាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ក្នុងករណីត្រូវរក្សាការសម្ងាត់របស់រដ្ឋ ឬសីលធម៌សង្គម ការជំនុំជំរះអាចធ្វើជាសម្ងាត់បាន តែសាលក្រម ត្រូវប្រកាសជាសាធរណៈ ។ តុលាការត្រូវប្រកាសជាជំនុំជំរះជាសម្ងាត់ដោយសេចក្តីសំរេចមានមូលហេតុ ។

ទោះបីការជំនុំជំរះ ត្រូវធ្វើជាសាធារណៈក៏ដោយក៏មិនត្រូវអនុញ្ញាតិអោយអនីតិជន គឺជនអាយុតិចជា ១៨ ឆ្នាំ ចូលរួមស្តាប់ក្នុងសវនាការទេ លើកលែងតែអនីតិជននេះត្រូវតុលាការកោះមកសួរជាសាក្សី ។

សវនាការរបស់តុលាករប្រជាជន ត្រូវប្រព្រឹត្តទៅដូចខាងក្រោមនេះ:

**១-មុនបើកសវនាការ:**

លេខធិការ-ក្រឡាបញ្ជី មានភារកិច្ច :

ក-អានបទបញ្ជាផ្ទៃក្នុងនៃបន្ទប់ជំនុំជំរះ

ខ-ពិនិត្យវត្តមាននៃអ្នកចូលរួមក្នុងសវនាការទាំងអស់ ។ ក្នុងករណីអវត្តមាននៃសាមីជនណាម្នាក់ នោះត្រូវពិនិត្យរកមូលហេតុ ។

**២-ពេលបើកសវនាការ:**

- លេខធិការ-ក្រឡាបញ្ជី អញ្ជើញអ្នកចូលរួមក្នុងនីតិវិធីទាំងអស់ មកកាន់បន្ទប់សវនាការ
- ស្នូកណ្តឹង ៣ ដង ជាសញ្ញាប្រាប់អំពីការចូលបន្ទប់សវនាការនៃក្រុមប្រឹក្សាជំនុំជំរះ
- លេខាធិការ-ក្រសឡាបញ្ជី អញ្ជើញសាធារណៈជនក្រោកឈរ

-ក្រុមប្រឹក្សាជំនុំជំរះ ចូលមកកាន់កន្លែង ។ ប្រធានអញ្ជើញសាធារណជនអង្គុយរួចក្រុមប្រឹក្សា ជំនុំជំរះក៏អង្គុយភ្លាមដែរ ។

-ប្រធានក្រោកឈរប្រកាសបើការជំនុំជំរះ និងប្រកាសកម្មវត្ថុនៃរឿងហេតុព្រះទាំងឈ្មោះនៃគូភាគី ។

-ប្រធានបង្គាប់ឱ្យលេខាធិការ-ក្រឡាបញ្ជី រាយការណ៍ពីវត្តមាន និងអវត្តមាននៃអ្នកដែលត្រូវ ចូលរួមក្នុងនីតិវិធី ។

- លេខាធិការ-ក្រឡាបញ្ជី ក្រោកឈរ ហើយរាយការណ៍ ។ បើមានអ្នកចូលរួមណាមួយអវត្តមាន ឬបើមានសំណូមពរពីគូភាគីណាំស្នើផ្អាកសវនាការក្រុមប្រឹក្សាជំនុំជំរះ ត្រូវពិភាក្សា និងសំរេចថា តើគួរបន្តសវនាការ ឬបង្អង់ទៅថ្ងៃក្រោយ ។

- ប្រធានក្រោកឈរប្រកាសសមាសភាពតុលាការ ហើយសួរអត្តសញ្ញាណ គឺនាមត្រកូល និងឈ្មោះ អាយុ សញ្ជាតិ លំនៅដ្ឋានបច្ចុប្បន្ន របររកស៊ី ឈ្មោះប្តី ប្រពន្ធ រួចប្រាប់សិទ្ធិ និងកាតព្វកិច្ចដល់គូភាគី ។ បន្ទាប់ មកប្រធាន សួរដល់ភាគីម្នាក់ៗតើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាជំនុំជំរះរូបណាមួយទេ ។ ប្រសិនបើមាន ក្រុមប្រឹក្សាជំនុំជំរះទាំងមូលជាអ្នកពិនិត្យ និងសំរេចតាមមតិភាគច្រើន ក្រោយពីបានយោបល់ពីតំណាងអយ្យការ

ក្នុងករណីដែលរដ្ឋអាជ្ញាតាំងខ្លួនជាគូក្ដីដើម ។ ការប្ដឹងសុំផ្លាស់ប្ដូរ និងទុកជាបានការ លុះត្រាតែបណ្ដឹងនោះមានមូលហេតុត្រឹមត្រូវ ។

-ប្រធាន ប្រាប់ដល់អ្នកចូលរួមឯទៀត ដូចជាសាក្សី អ្នកជំនាញដែលបានធ្វើកោសល្យវិច័យ អ្នកបកប្រែ អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ។

**៣-ការសួរដេញដោល :**

-ក្នុងដំណាក់កាលសួរដេញដោល ប្រធានក្រុមប្រឹក្សាជំនុំជំរះ សួរដេញដោលដើមចោទមុន បន្ទាប់មកចុងចម្លើយ និងអ្នកចូលរួមឯទៀត ។

-ក្នុងពេលប្រធានសួររួច ប្រធានត្រូវប្រគល់សំដី អោយទីប្រឹក្សាសួរបន្ថែម

-បន្ទាប់ពីទីប្រឹក្សាប្រជាជន តំណាងអយ្យការ អ្នកការពារ មានសិទ្ធិតាំងសំណួរបានប្រសិនបើមាន ។

-បើក្នុងសំណុំរឿងមានបណ្ដឹងរបស់តំណាងអយ្យការ ដែលតាំងខ្លួនជាគូក្ដីដើម ប្រធានសវនាការត្រូវអធិប្បាយដោយសង្ខេបនូវខ្លឹមសារនៃបណ្ដឹងរបស់តំណាងអយ្យការ ។ បន្ទាប់មកប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវបង្គាប់អោយលេខាធិការ ក្រឡាបញ្ជី អានទាំងស្រុងនូវបណ្ដឹងរបស់តំណាងអយ្យការ ។ ប្រធានអញ្ជើញតំណាងអយ្យការ មានមតិបន្ថែម ។

ប្រធាន អាចបង្គាប់អោយលេខាធិការ ក្រឡាបញ្ជី អានចម្លើយរបស់អ្នកវត្តមាន ដែលគេបានឆ្លើយនៅពេលអង្កេតស៊ើបសួររួចហើយ ។

គូភាគី សក្សា ដែលជាជនជាតិមានសិទ្ធិប្រើភាសារបស់ខ្លួនបាន នៅពេលជំនុំជំរះ តែត្រូវឱ្យមានអ្នកបកប្រែភាសា ។

កំណត់សំគាល់ប្រធាន ត្រូវចេះឆក់ឱកាសក្នុងពេលសួរសាម៉ីជនបញ្ចេញវត្ថុតាង ឬឯកសារនានា ដែលទាក់ទងនឹងសាម៉ីជននោះ ហើយសួរបញ្ជាក់តើគេទទួលស្គាល់ឯកសារ ឬវត្ថុតាងទាំងនោះប្រាកដមែនឬទេ ។

**៤-ការសួរតទល់គ្នា:**

-ក្នុងតំណាក់ការសួរតទល់គ្នា ប្រធានក្រុមប្រឹក្សាជំនុំជំរះ ត្រូវទុកសិទ្ធិឱ្យដើមចោទចុងចម្លើយ និងអ្នកចូលរួមឯទៀត ជជែកតទល់ចំពោះចំណុចទាំងឡាយណាដែលគេពុំឯកភាពគ្នា ។ ប្រធានត្រូវធ្វើការណែនាំឱ្យសាម៉ីជនចេះអធិប្បាយវែកញែកហេតុផលនៃដំណើររឿង ដើម្បីការពារសិទ្ធិ និងប្រយោជន៍ស្របច្បាប់របស់គេ ហើយប្រធានត្រូវចេញកាត់សំដីណា ដែលវែងអន្លាយ ឬការជជែកគ្នាខុសខ្លឹមសារនៃរឿង ។

-ក្នុងករណីដែលតំណាងអយ្យការ តាំងខ្លួនជាគូក្ដីដើម តំណាងអយ្យការអាចជជែកតទល់ជាមួយចុងចម្លើយ និងសាក្សីរបស់ចុងចម្លើយ ។

-បន្ទាប់មកប្រធាន ត្រូវអញ្ជើញអ្នកការពារសិទ្ធិដើមចោទ ធ្វើសេចក្តីសន្និដ្ឋាន រួចទើបអញ្ជើញ អ្នកការពារសិទ្ធិចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានតបវិញប្រសិនបើមាន ។

-ចុងក្រោយបង្អស់ប្រធានសវនាការ អញ្ជើញតំណាងអយ្យការ សន្និដ្ឋានវាយតម្លៃ និងធ្វើសំណូមពរ ។

-ប្រធាន ប្រកាសបញ្ចប់ដំណាក់កាលសួរតទល់

-ក្រុមប្រឹក្សាជំនុំជំរះ ថយចូលក្នុងបន្ទប់ពិភាក្សា ។

**៥-ការពិភាក្សាក្នុងបន្ទប់សម្ងាត់ :**

ក្រុមប្រឹក្សាជំនុំជំរះ ត្រូវពិនិត្យនូវបញ្ហាដូចខាងក្រោមនេះ :

ក- ទំនាក់ទំនងគតិយុត្តិ រវាងដើមចោទ និងចុងចម្លើយ និងសាម៉ីជនឯទៀត

ខ- ភស្តុតាងគ្រប់គ្រាន់ហើយ ឬនៅ?

គ- សិទ្ធិ និងកាតព្វកិច្ច របស់សាម៉ីជនម្នាក់ៗ ដែលត្រូវដោះស្រាយតាមបញ្ញត្តិច្បាប់ និងគោលនយោបាយរបស់បក្ស ។

ប្រធានមានភារកិច្ចអធិប្បាយបញ្ហានីមួយៗ និងបញ្ញត្តិច្បាប់ គោលនយោបាយរបស់បក្ស ជូនសមាជិកក្រុមប្រឹក្សាជំនុំជំរះ ត្រូវផ្តល់មតិមុន រួចទើបប្រធានក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមមតិភាគច្រើន ។ ក្នុងករណីមានមតិមិនឯកភាពគ្នា ប្រធាន ត្រូវធ្វើកំណត់ហេតុដាក់ក្នុងសំណុំរឿង រីឯអ្នកមានមតិមិនឯកភាព ក៏មានសិទ្ធិសរសេរមតិរបស់ខ្លួនដាក់ចូលក្នុងសំណុំរឿងដែរ ។

នៅពេលពិភាក្សា គ្មានជនណាមានសិទ្ធិចូលក្នុងបន្ទប់សម្ងាត់ ក្រៅពីក្រុមប្រឹក្សាជំនុំជំរះឡើយ ។

**៦-ការប្រកាសសាលក្រម:**

ស្នូរកណ្តឹង ៣ ដង

-ក្រុមប្រឹក្សាជំនុំជំរះ ចេញពីបន្ទប់សម្ងាត់ មកកាន់បន្ទប់សវនាការវិញ ។

-ប្រធានក្រោកឈរ ដើម្បីអានសាលក្រម ។ ព្រមជាមួយនោះលេខាធិការ ក្រឡាបញ្ជី អញ្ជើញសាធារណជនក្រោកឈរ ។

-លុះអានចប់សមាសភាពតុលាការហើយ ប្រធាន អញ្ជើញសាធារណជនអង្គុយ ។

-ក្នុងពេលតុលាការប្រកាសសេចក្តីវិនិច្ឆ័យ លេខាធិការ ក្រឡាបញ្ជី អញ្ជើញសាធារណជនក្រោកឈរ ។

-លុះប្រកាសសាលក្រមចប់ ប្រធាន អញ្ជើញសាធារណជនអង្គុយ ។ ប្រធានក៏អង្គុយដែរ ។

-ប្រធាន ប្រាប់ទៅគូភាគី បើមិនសុខចិត្តនឹងសាលក្រមនេះទេ អាចធ្វើពាក្យប្តឹងទៅក្រសួងយុត្តិធម៌បាន ។

-ប្រធានក្រោកឈរ ប្រកាសបិទសវនាការ ។

V ~ **ក្រោយពេលសវនាការ :**

-ប្រធានសវនាការ ត្រូវពិនិត្យឡើងវិញ នូវកំណត់ហេតុក្នុងសៀវភៅសវនាការ ។ កំណត់ហេតុសវនាការ ឆ្លុះបញ្ចាំង និងបញ្ជាក់សព្វគ្រប់ អំពីការដែលកើតមានក្នុងពេលសវនាការ ។

កំណត់ហេតុសវនាការ ត្រូវមានហត្ថលេខា របស់លេខាធិការ-ក្រឡាបញ្ជីកត់ត្រា និងក្រុមប្រឹក្សាជំនុំជំរះ ។

-លេខាធិការ-ក្រឡាបញ្ជី ត្រូវចម្លងកំណត់ហេតុសវនាការ រួចយកមកទុកក្នុងសំណុំរឿង ។

-ក្រោយពេលសវនាការ ចៅក្រម ត្រូវចាត់ឱ្យលេខាធិការ-ក្រឡាបញ្ជីចម្លងសាលក្រម ជូនតំណាងអយ្យការ និងក្រសួងយុត្តិធម៌ជាបន្ទាន់ ព្រមទាំងផ្ញើសំរង់សាលក្រម ឬចម្លងសាលក្រមជូនគូភាគី និងអង្គការមានសមត្ថកិច្ចដើម្បីអនុវត្ត ។

-ការអនុវត្តន៍សាលក្រម ត្រូវប្រព្រឹត្តទៅតាមសារាចរ លេខ ១០២៦ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៨២ របស់ក្រសួងយុត្តិធម៌ ដែលបានផ្ញើជូនដល់អយ្យការ និងតុលាការប្រជាជនខេត្ត ក្រុងរួចហើយ ។

# កំណត់សំគាល់

## I ~ ការប្តឹងជំទាស់ និងការជំនុំជំរះសារឡើងវិញ

### ១-ការប្តឹងជំទាស់

សាលក្រមរដ្ឋប្បវេណី របស់តុលាការប្រជាជនខេត្ត ក្រុង ដែលសំរេចចំពោះមុខមានអានុភាពអនុវត្តភ្លាម១ ។ សាលក្រមកំបាំងមុខ គ្មានអនុភាពអនុវត្តចំពោះមុខភាគីអនុវត្តមានបានទេ ។ ភាគីអវត្តមានអាចប្តឹងជំទាស់នឹងសាលក្រមនេះ បានក្នុងរយៈ ១៥ ថ្ងៃ គិតពីថ្ងៃដែលបានអោយដំណឹងពីសាលក្រមនោះដល់សាមីខ្លួនផ្ទាល់ ឬដល់ទីលំនៅរបស់សាមីខ្លួន ។

បើផុតរយៈពេលនេះ ភាគីអវត្តមាន ដែលបានទទួលដីកាឱ្យដំណឹងហើយ តែមិនប្តឹងជំទាស់ នោះសាលក្រមកំបាំងមុខ និងទៅជាសាលក្រមស្ថាពរ ។

បើភាគីអវត្តមាន ប្តឹងជំទាស់ក្នុងរយៈពេលកំណត់ នោះប្រធានតុលាការត្រូវកោះហៅអ្នកប្តឹងទាស់ព្រមទាំងភាគីដទៃទៀត ឱ្យចូលខ្លួនមកពេនាំពេលជំនុំជំរះ ដែលនឹងកំណត់ធ្វើនៅថ្ងៃណាមួយខាងមុខ ។

បើអ្នកប្តឹងទាស់មិនព្រមចូលខ្លួនមកទៀត ក្រោយពីបានទទួលដីកាកោះត្រឹមត្រូវហើយ នោះការប្តឹងជំទាស់របសាមីជន ត្រូវទុកជាអសារឥតការ ។ ក្នុងករណីនេះ សាលក្រមកំបាំងមុខ ត្រូវទៅជាសាលាក្រមស្ថាពរ ហើយត្រូវយកទៅអនុវត្ត ។

**២-ការជំនុំជំរះសារឡើងវិញៈ**

បើរដ្ឋអាជ្ញាយល់ឃើញថា សាលក្រមរដ្ឋប្បវេណីរបស់តុលាការប្រជាជនខេត្ត ក្រុងសំរេចដោយមានការភាន់ច្រឡំ រដ្ឋអាជ្ញា ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងសំរេច ។

ក្នុងនីតិវិធីជំរះសាឡើងវិញ ក្រុមប្រឹក្សាជំនុំជំរះ ត្រូវមានចៅក្រម ២ នាក់ ដែលម្នាក់ជាប្រធាន និងទីប្រឹក្សាប្រជាជន ៣ នាក់ ហើយសុទ្ធតែអ្នកដែលមិនបានចូលរួមក្នុងការជំនុំជំរះលើកមុន ។

សាលក្រមរបស់តុលាការប្រជាជនខេត្ត ក្រុង ដែលជំនុំជំរះសារឡើងវិញ ទោះបីសំរេច កំបាំងមុខក៏ដោយ ក៏មិនអាចឱ្យមានការប្តឹងជំទាស់ ឬតវ៉ាទៀតឡើយ ។

**II ~ ឧប្បត្តិហេតុក្នុងអំឡុងនីតិវិធី**

**១-វិធានការបណ្តោះអាសន្នៈ**

ចាប់តាំងពីពេលទទួលពាក្យបណ្តឹង រហូតដល់ពេលជំនុំជំរះ ចៅក្រមមានសិទ្ធិចេញដីការសំរេចជាការប្រញាប់ តាមដាមសំណូមពររបស់របស់គូភាគី ប្រសិនបើយល់ឃើញថាចាំបាច់ ។ ដីការសំរេចនេះមានគោលដៅបង្កាកាអន្តរាយផេសង១ ដែលអាចកើតមានជាយថាដូចជាដីការសំរេចឱ្យប្តី និងប្រពន្ធ ដែលសុំលះលែងគ្នា បែកលំនៅពីគ្នាជាបណ្តោះអាសន្នដីកាសំរេចឱ្យភាគីម្ខាងចិញ្ចឹមអាហារកិច្ចកូនជាបណ្តោះអាសន្ន ។ ដីកាសំរេចឱ្យកត់ទ្រព្យសម្បត្តិ និងប្រគល់សិទ្ធិដល់ជនណាម្នាក់ ឱ្យថែរក្សាជាបណ្តោះអាសន្ន នូវទ្រព្យសម្បត្តិដែលមានទំនាស់ ឬទ្រព្យសម្បត្តិសំរាប់ការពារផលប្រយោជន៍របស់គូភាគី ។

ចៅក្រម ចេញដីកាសំរេចជាការប្រញាប់បាន ចំពោះតែកិច្ចការជាបណ្តោះអាសន្ន ដែលមិនបានប៉ះពាល់ទៅដល់អង្គសេចក្តី ។ ដីកាសំរេចនេះ មិនអាចប្តឹងជំទាស់បានឡើយ ។

**២- ការបញ្ចូលតតិយជនមកជាគូក្តី**

នៅពេលធ្វើការសួរដេញដោល បើមានតតយជនណាជាប់ទាក់ទងក្នុងរឿងដែលតុលាការកំពុងជំនំជំរះ នោះតុលាការអាចបញ្ចូលឈ្មោះតតិយជននេះ មកជាគូក្តីខាងដើមចោទ ឬខាងចុងចំលើយ យោលទៅតាមផលប្រយោជន៍ របស់ភាគីនីមួយ១ ។

**៣- ការធ្វើបន្តឡើងវិញនូវការជំនុំជំរះ**

នៅពេលពេលជំនុំជំរះ ប្រសិនបើដើមចោទបានទទួលអនិច្ចកម្ម នោះតុលាការត្រូវស្រាវជ្រាវរកដោយគ្រប់មធ្យោបាយនូវទាយាទទាំងឡាយនៃសព ។ ទាយាទទាំងនោះត្រូវកោះហៅមកចំពោះមុខតុលាការ ហើយតុលាការត្រូវសួរឱ្យដឹងថា ទាយាទទាំងនោះមានបំណងបន្តក្តីទៅទៀត ឬក៏បោះបង់ត្រឹមនេះ ។

ក្នុងករណីទី ១ វិនាទកម្មត្រូវធ្វើឡើងវិញ ក្នុងនាមទាយាទទាំងនោះ តុលាការត្រូវបញ្ចូលឈ្មោះទាយាទទាំងនោះ មកជាគូក្ដីខាងដើមចោទ

ក្នុងករណីទី ២ វិនាកម្មត្រូវតែរំលាយចោល ហើយប្រដាប់ប្ដឹងទាំងឡាយ ដែលបង់រួចហើយ ត្រូវទុកឱ្យអ្នកទទួលមតិក របស់ដើមចោទ ។

នៅពេលជំនុំជំរះ ប្រសិនបើចុងចំលើយបានទទួលអនិច្ចកម្ម ហើយដើមចោទ ប្ដឹងសុំឱ្យទាយាទរបស់ចុងចំលើយ ជួសជុលសំនងនោះ តុលាការត្រូវស្រាវជ្រាវរកដោយគ្រប់មធ្យោបាយនូវទាយាទទាំនោះ រួចបញ្ចូលឈ្មោះទាយាទទាំងនោះ មកជាគូក្ដីខាងចុងចំលើយដើម្បីតក្ដី ។

### ៤- ការដំកល់រឿងទុកមិនចាត់ការ

ចៅក្រម អាចតំកល់រឿងទុកមិនចាត់ការ ក្នុងករណីដូចខាងក្រោម :

ក. មានប្ដឹងគ្នាម្ដងរួចមកហើយ តុលាការបានសំរេចម្ដងរួចមកហើយស្រាបតែមានប្ដឹងទៀតនូវរឿងដដែល ។

ខ. នៅមុនពេលជំនុំជំរះ ដើមចោទសុខចិត្តដកពាក្យបណ្ដឹងរបសលខ្លួន ហើយបណ្ដឹងនេះពតក៏គ្មានប៉ះពាល់ដល់ប្រយោជន៏ដល់អង្គការរដ្ឋ ឬអង្គការមហាជណណាមួយឡើយ ។

អ្នកចំណាយក្ដី អាចឈប់ប្ដឹងជំនួសកូនក្ដីបាន លុះត្រាតែមានសំបុត្រប្រគល់សិទ្ធិជាពិសេសពីកូនក្ដីរបស់ខ្លួន ដែលអនុញាតិឱ្យឈប់ប្ដឹង ។

### ៥- ការបង្អង់រឿងទុកមួយអន្លើ ការបង្អង់ការជំនុំជំរះ

តុលាការអាចបង្អង់ទុកមួយអន្លើ នូវរឿងដូចខាងក្រោម :

ក. នៅពេលជំនុំជំរះ ស្រាប់តែភាគីណាមួយមានជំងឺរិកលចរិក ។ ក្នុងករណីនេះត្រូវរងចាំឱ្យភាគីនោះជាស្រលះសិនសឹមជំនុំជំរះ ។

ខ. ដើមចោទអវត្តមានយូរ ហើយមិនបានប្រគល់សិទ្ធិឱ្យជនណាម្នាក់ប្ដឹងជំនួលខ្លួន ឬពុំដឹងអាស័យដ្ឋានពិតប្រាកដរបស់ជននោះ ។

ករណីនេះតុលាការអាចនឹងជំនុំរះបាន លុះត្រាតែដើមចោទនោះត្រឡប់មកវិញ ។

គ. នៅពេលជំនុំជំរះ បើឃើញថាក្នុងរឿងរដ្ឋប្បវេណីនេះ មានភាគីណាមួយប្ដឹងបទព្រហ្មទណ្ឌនៅមន្ទីរអយ្យការ ហើយអយ្យការក៏បានចោទប្រកាន់រួចហើយដែលនោះ តុលាការត្រូវបង្អង់ការជំនុំជំរះសិន ។

តុលាការរដ្ឋប្បវេណី អាចជំនុំជំរះទៅទៀតបាន លុះត្រាតែតុលាការព្រហ្មទណ្ឌបានដសសំរេចសេចក្ដីអំពីបណ្ដឹងរបស់គូភាគីនោះរួចស្រេចជាស្ថាពរ ។

ក្រសួងយុត្តិធម៌សង្ឃឹមថា សេចក្តីណែនាំខាងលើនេះ អាចជួយដល់សមមិត្តប្រធាន អនុប្រធានចៅក្រម និងរដ្ឋអាជ្ញា នៅគ្រប់តុលាការប្រជាជន ខេត្ត ក្រុង ក្នុងការអនុវត្តភារកិច្ចរៀង១ខ្លួន ។ ក្នុងករណីជួបការលំបាក សូមសមមិត្តលើកជាមតិស្នើរឡើងក្រសួងតុត្តិធមិ ក្រសួងយុត្តិធម៌នឹងធ្វើការណែនាំបន្ថែមតាមសំណូមពរ ។

ហត្ថលេខា និង ត្រា

**អ៊ុក ប៊ុនឈឿន**